# ក្រសួងមុខងារសាធារណៈ

## អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

# លទ្ធផលការងារ
# បញ្ហាប្រឈមនិងទិសដៅការងារ
# រយៈពេល៥ឆ្នាំ

# មាតិកា

១. សេចក្ដីផ្ដើម

២. លទ្ធផលការងារ

៣. បញ្ហាប្រឈម

៤. ទិសដៅការងារបន្ត

# ១. សេចក្តីផ្តើម

អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុមានភារកិច្ចដឹកនាំ គ្រប់គ្រង និងសម្របសម្រួលកិច្ចការរដ្ឋបាល ការគ្រប់គ្រងបុគ្គលិក ផែនការ ហិរញ្ញវត្ថុ ផ្គត់ផ្គង់ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

# ២. លទ្ធផលការងារ

ក្នុងរយៈពេល៥ឆ្នាំនៃការអនុវត្តការងារ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុសម្រេចបានលទ្ធផលមានជាអាទិ៍៖

## ២.១. ការអភិវឌ្ឍស្ថាប័នក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ

- ក្រសួងបានរៀបចំនិងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តសំខាន់ៗ ដើម្បីធានាដល់ការអនុវត្តដែនសមត្ថកិច្ចរបស់ខ្លួនទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ រួមមាន៖
  - ច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
  - អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ

- ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃការិយាល័យចំណុះនាយកដ្ឋាននិងអង្គភាពនានានៃអគ្គនាយកដ្ឋាននិងអគ្គាធិការដ្ឋាន
- ព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៩៥ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការផ្ទេរសាលាភូមិន្ទរដ្ឋបាលឱ្យស្ថិតនៅក្រោមចំណុះរបស់ក្រសួងមុខងារសាធារណៈ
- ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាននានានៃសាលាភូមិន្ទរដ្ឋបាល
- ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមន្ទីរមុខងារសាធារណៈទាំង២៥រាជធានី ខេត្ត

- រៀបចំ និងដាក់ឱ្យដំណើរការក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្ស របស់រាជរដ្ឋាភិបាល គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងមុខងារសាធារណៈ
- បានរៀបចំ និង ដាក់ឱ្យអនុវត្តជាផ្លូវការប្រព័ន្ធគ្រប់គ្រងចរន្តឯកសារនៅក្នុងក្រសួងមុខងារសាធារណៈ និងកំពុងធ្វើបច្ចុប្បន្នភាព ដើម្បីដាក់ប្រព័ន្ធឱ្យដំណើរការនៅតាមមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត។
- បានរៀបចំរចនាសម្ព័ន្ធការងាររបស់មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត

# ប្រព័ន្ធគ្រប់គ្រងចរន្តឯកសារ

ខ្មែរ English

3 ទំព័រដើម | ទំព័ររបស់ខ្ញុំ | ឯកសាររបស់ខ្ញុំ | ក្រុម | សមាជិក | ចាកចេញ

បង្កើតឯកសារថ្មី

សៀវភៅចូល

ស្វែងរកឯកសារ

- មិនទាន់មានលេខចេញ Reset
- មានលេខចេញ

ស្វែងរកពាក្យ:

ថ្ងៃខែឆ្នាំចូល:

មកពី:

លេខចូល 349 (ប្រហែល 1 ខែមុន)

កែ ✖មានលេខចេញមិនអាចលុបបាន

ថ្ងៃផុតកំណត់: --- (ឯកសារប្រញាប់)

| | |
|---|---|
| លេខលិខិតដើម: | ០០១៨ផក |
| មកពី: | ក្រសួងផែនការ |
| អង្គភាព/ផ្សេងៗ: | |
| ថ្ងៃខែឆ្នាំដើម: | ថ្ងៃទី09 ខែមករា ឆ្នាំ2018 |
| កម្មវត្ថុ: | សំណើសុំរៀបចំគម្រោងសម្រាប់ដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគសធារណៈ(ក.វ.ស)៣ឆ្នាំរំកិល ២០១៩-២០២១ |
| ថ្ងៃខែឆ្នាំចូល: | ថ្ងៃទី11 ខែមករា ឆ្នាំ2018 ម៉ោង10:23 |
| អ្នកបញ្ចូល: | បូរ៉ែន |
| អ្នកទទួលបន្ទុក: | --- |

តាមដាន

- បានចុះលេខចូល
  ប្រហែល 1 ខែមុន
- បានជូនដំណឹង
  ប្រហែល 1 ខែមុន by: បូរ៉ែន
- កែបន្ថែម
  ប្រហែល 1 ខែមុន by: បូរ៉ែន
- កែបន្ថែម
  29 ថ្ងៃមុន by: ពេជ សុម្មនី
- កែបន្ថែម
  28 ថ្ងៃមុន by: ម៉េង ម៉ង់ទិត
- បានចុះលេខចេញ 641 (លោក សែម វណ្ណៈ)
  6 នាទីមុន
- បញ្ចប់
  5 នាទីមុន by: ស្រីន

# ២.២- ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស

– ត្រឹមខែមករា ឆ្នាំ២០១៨ មន្ត្រីរាជការស៊ីវិល នៃក្រសួងមុខងារសាធារណៈមានចំនួនសរុប**៨១៩**នាក់ (ស្ត្រី**២៤៦**នាក់ ស្មើនឹង**៣០%**) ក្នុងនោះមន្ត្រីរាជការនៅថ្នាក់ជាតិមានចំនួន**៤៩៥**នាក់ ស្មើនឹង**៦០%** ថ្នាក់ក្រោមជាតិមានចំនួន**៣២៤**នាក់ ស្មើនឹង**៤០%** និងជនពិការចំនួន**១៥**នាក់

– ស្ថានភាពប្រែប្រួលមន្ត្រីរាជការស៊ីវិលក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈមានចំនួន**៣.៦៩១**ករណី

– បានបញ្ជូនមន្ត្រីរាជការ ចូលរួមវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាក្នុងប្រទេសចំនួន**២.០៦៤**នាក់ (ស្ត្រី**៤៥៣**នាក់) និងក្រៅប្រទេសចំនួន**៦២៦**នាក់ (ស្ត្រី**៨៤**នាក់)។

# ២.៣-ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

សមិទ្ធផលសំខាន់ៗសម្រេចបានរួមមាន៖

– បានសាងសង់អគារទីស្តីការក្រសួងចំនួន០១ខ្នងមានកំពស់០៦ជាន់ និងសាងសង់អគារប្រជុំមួយខ្នងមាន០២បន្ទប់ ដណ្ដើរយន្តចំនួន០២ រៀបចំរបងក្រសួងថ្មី ធ្វើតូបយាម ជម្រាលសម្រាប់ជនពិការ រៀបចំប្រព័ន្ធលូបួរស្លាក ដំបូលតភ្ជាប់អគារចាស់ទៅថ្មី ចំណតរថយន្តកែលម្អសួនច្បារ និងដាំដើមឈើ

- បានរៀបចំតបណ្តាញ Network បណ្តាញ Server ថ្មី និងបណ្តាញប្រព័ន្ធធាតុត្រជាក់ (Cooling System) ព្រមទាំងបំពាក់កាមេរ៉ាសុវត្ថិភាពសម្រាប់អគារថ្មីនៅទីស្តីការក្រសួងមុខងារសាធារណៈ
- បានជួសជុលសាលតម្កល់ឯកសារមន្ត្រីរាជការ បន្ទប់ Server រៀបចំប្រព័ន្ធអគ្គិសនី និងបំពាក់បំពង់ពន្លត់អគ្គីភ័យ
- បានរៀបចំកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសាលាភូមិន្ទរដ្ឋបាល ព្រមទាំងបំពាក់សម្ភារៈគរុកោសល្យនៅតាមបន្ទប់សិក្សា ដាក់អំពូលសូឡាបំភ្លឺតាមសួនច្បារ ចំណតយានយន្ត និងជួសជុលសហសាល

- បានសាងសង់ស្តូប ព្រះព្រហ្មមុខបួន និងអគារសិក្សាថ្មីកម្ពស់០៥ជាន់ នៅសាលាភូមិន្ទរដ្ឋបាល
- បានសាងសង់របងវិទ្យាស្ថានមុខងារសាធារណៈភូមិភាគនៅខេត្តត្បូងឃ្មុំ
- បានទិញដីនិងអគារមន្ទីរមុខងារសាធារណៈខេត្តព្រៃវែង
- បានសាងសង់អគារមន្ទីរមុខងារសាធារណៈចំនួន១០ គឺ ខេត្តរតនគិរី ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តស្ទឹងត្រែង ខេត្តកោះកុង ខេត្តឧត្តរមានជ័យ

ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តត្បូងឃ្មុំ និងខេត្តប៉ៃលិន

– បានជួសជុលអគារមន្ទីរមុខងារសាធារណៈចំនួន៩ គឺខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ ខេត្តកោះកុង ខេត្តប៉ៃលិន ខេត្តកំពង់ស្ពឺ ខេត្តតាកែវ និងខេត្តកែប

– បានទិញរថយន្តចំនួន៧គ្រឿង ទោចក្រយានយន្តចំនួន២គ្រឿង និងទិញម៉ាស៊ីនភ្លើងចំនួន២គ្រឿង

## ២.៤- ការកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ក្រសួងបានខិតខំកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយទទួលបានសមិទ្ធផលដូចខាងក្រោម៖

- បានរៀបចំរចនាសម្ព័ន្ធថវិកាទៅតាមកម្មវិធីដែលមានគោលបំណងគោលនយោបាយចំនួន០២ កម្មវិធីចំនួន ០៤ និងអនុកម្មវិធីចំនួន១៦។
- បានរៀបចំអង្គភាពថវិកាចំនួន២៩ ក្នុងនោះអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធចំនួន២៦អង្គភាព និងអង្គភាពថវិកាអាណាប័កមិនផ្ទេរសិទ្ធចំនួន០៣។

- បានរៀបចំ និង ដាក់ឱ្យអនុវត្តសេចក្តីណែនាំស្តីពីគោលការណ៍ និងនីតិវិធីផ្ទៃក្នុងនៃការអនុវត្តថវិកាតាមកម្មវិធីរបស់ក្រសួងមុខងារសាធារណៈ
- បានរៀបចំផែនការសកម្មភាព ដំណាក់កាលទី៣ ( MAP3 )២០១៦-២០១៨,( MAP3 )២០១៧-២០១៩ និង (MAP3)២០១៨-២០២០ ព្រមទាំងអនុវត្ត MAP3 ទទួលបានចំណាត់ថ្នាក់ល្អប្រសើរ ក្រោមការវាយតម្លៃរបស់ អគ្គលេខាធិការដ្ឋានគណៈកម្មាធិកាដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី យុទ្ធសាស្ត្រថវិកា ថវិកាកម្មវិធី កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ស្តីពីការអនុវត្តថវិកាកម្មវិធីចំនួន៩វគ្គ ដល់ថ្នាក់ដឹកនាំគ្រប់កម្រិត និងមន្ត្រីជំនាញនៃអង្គភាពថវិកាទាំង២៩ ដែលមានសិក្ខាកាមសរុបចំនួន៦៣៥នាក់
- បានអនុវត្តប្រព័ន្ធ FMIS ដំណាក់កាលសាកល្បងនៅទីស្តីការក្រសួងមុខងារសាធារណៈ
- បានបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងមុខងារសាធារណៈ តាមប្រព័ន្ធធនាគារ កាណាឌីយ៉ា បានទាន់ពេលក្នុងសប្តាហ៍ទី៤នៃខែនីមួយៗ។

# ៣. បញ្ហាប្រឈម

- ចំនួនមន្ត្រីរាជការនៅក្នុងរចនាសម្ព័ន្ធការងាររបស់មន្ទីរមុខងារសាធារណៈរាជធានី   ខេត្តនៅមានចំនួនតិចដែលមិនទាន់ឆ្លើយតបទៅនឹងទំហំការងាររបស់មន្ទីរ
- មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត មួយចំនួនពុំទាន់មានអគាររដ្ឋបាលសមស្របដើម្បីបំពេញការងារនៅឡើយ

# ៤. ទិសដៅការងារបន្ត

- បន្តពង្រីក និង ពង្រឹងសមត្ថភាពសាលាភូមិន្ទរដ្ឋបាល និងការបង្កើតវិទ្យាស្ថានមុខងារសាធារណៈភូមិភាគ
- បន្តការងារសាងសង់អគាររដ្ឋបាលមន្ទីរមុខងារសាធារណៈ រាជធានី ខេត្ត
- បន្តរៀបចំវគ្គបណ្តុះបណ្តាលប្រព័ន្ធ គ្រប់គ្រង ចរន្តឯកសារ និងដាក់ឱ្យអនុវត្តសាកល្បងនៅតាមបណ្តាមន្ទីរមុខងារសាធារណៈមួយចំនួន ដែលជាគោលដៅរបស់ក្រសួង

– ពង្រឹងសមត្ថភាពមន្ត្រីជំនាញរបស់ក្រសួង និងអង្គភាពថវិកាទាំង២៩ លើការរៀបចំផែនការយុទ្ធសាស្ត្រថវិការបាយការណ៍សមិទ្ធកម្ម កម្មវិធីចំណូល-ចំណាយ និងកិច្ចបញ្ជិកាគណនេយ្យឱ្យកាន់តែប្រសើរឡើង។

# សូមអរគុណចំពោះការយកចិត្តទុកដាក់!